ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៤៩៥.....សហវ

ប្រកាស
ស្តីពី
ការអនុវត្តអាការលើតម្លៃបន្ថែម
លើការផ្គត់ផ្គង់ផលិតផលកសិកម្មមិនធាន់កែច្លៃ

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាការលើតម្លៃបន្ថែម
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១ ស្តីពីការធ្វើវិសោធនកម្មលើមាត្រា ៣១ នៃអនុក្រឹត្យស្តីពីអាការលើតម្លៃបន្ថែម លេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៥៦ នៃអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាការលើតម្លៃបន្ថែម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, COMBODIA.
ទូរស័ព្ទ: ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

សម្រួច

ប្រការ ១.- គោលបំណង

ប្រកាសនេះ មានគោលបំណងកំណត់អំពីយន្តការអនុវត្តអាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់ផលិតផលកសិកម្មមិនទាន់កែច្នៃ ស្របតាមអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៥៦ នៃអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម។

ប្រការ ២.- គោលដៅ

ប្រកាសនេះ មានគោលដៅដាក់ចេញនូវយន្តការលើកលែងអាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់ផលិតផលកសិកម្មមិនទាន់កែច្នៃ ដើម្បីគាំទ្រដល់គោលនយោបាយនាំចេញអង្ករបស់រាជរដ្ឋាភិបាល និងសម្រាលបន្ទុកចំណាយរបស់ប្រជាជនក្នុងការប្រើប្រាស់ផលិតផលកសិកម្មមិនទាន់កែច្នៃ ដែលក្នុងនោះមានគ្រាប់ធញ្ញជាតិនានា រួមទាំងស្រូវអង្ករផង។

ប្រការ ៣.- វិសាលភាព

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការផ្គត់ផ្គង់ផលិតផលកសិកម្មមិនទាន់កែច្នៃ ដោយបុគ្គលជាប់អាកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ ៤.- និយមន័យ

សម្រាប់គោលដៅនៃប្រកាសនេះ ÷

១- ពាក្យ "ផលិតផលកសិកម្មមិនទាន់កែច្នៃ" សំដៅដល់ បូស មើម ដើម សំបក ផ្លែ ផ្កា ឬគ្រាប់ នៃរុក្ខជាតិ ដែលបានមកពីការធ្វើកសិកម្មដាំដុះ ទោះមិនទាន់កិនឬកិនបំបែករួចហើយក្តី និងដែលមិនទាន់ត្រូវបានយកទៅកែច្នៃជាផលិតផលផ្សេង។

២- ពាក្យ "ផ្គត់ផ្គង់" សំដៅដល់ ÷

ក. ការលក់ផលិតផលកសិកម្មមិនទាន់កែច្នៃ ដោយបុគ្គលជាប់អាកនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ខ. ការដកយកផលិតផលកសិកម្មមិនទាន់កែច្នៃ មកប្រើប្រាស់ផ្ទាល់ខ្លួនដោយបុគ្គលជាប់អាករ

គ. ការផ្តល់ជាអំណោយឬការលក់ក្រោមតម្លៃពិតនូវផលិតផលកសិកម្មមិនទាន់កែច្នៃ ដោយបុគ្គលជាប់អាករ

ឃ. ការនាំចូលផលិតផលកសិកម្មមិនទាន់កែច្នៃ មកក្នុងតំបន់ត្រួតពិនិត្យគយនៃព្រះរាជាណាចក្រកម្ពុជា។

៣- ពាក្យ "បុគ្គលជាប់អាករ" សំដៅដល់បុគ្គលទាំងឡាយដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស។

ប្រការ ៥.- ការលើកលែងអាករលើតម្លៃបន្ថែម

ការផ្គត់ផ្គង់ផលិតផលកសិកម្មមិនទាន់កែច្នៃ ត្រូវបានចាត់ទុកថាជាការផ្គត់ផ្គង់មិនជាប់អាករ។

ប្រការ ៦.- ឥណទានអាករលើធាតុចូល

ឥណទានអាករលើធាតុចូលលើការនាំចូល ឬការទិញក្នុងស្រុក នូវសម្ភារៈនិងវត្ថុធាតុដើមសម្រាប់ធ្វើកសិកម្មជាំដុះផលិតផលកសិកម្មមិនទាន់កែច្នៃ ត្រូវអនុវត្តទៅតាមបទប្បញ្ញត្តិនៃមាត្រា ២៩ ដល់មាត្រា ៤១ នៃអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម។

ប្រការ ៧.- ការអនុវត្ត

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃអគ្គនាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់សហគ្រាសដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៦

បណ្ឌិត. អុន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ជូនចមាត្រា ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ